នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

# ជំងឺផ្តាសាយបក្សី



អាសយដ្ឋាន: #៧៤ មហាវិថី ព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (០២៣) ៤២៧ ៥៩០/ ៤២៦ ៩៧០
ទូរសារ : (០២៣) ៤២៦ ៩៧០/ ៤២៦ ១៦១

- ផ្តាសាយបក្សី ជាជំងឺឆ្លងដែលបង្កដោយ វីរុស និង បង្កជំងឺលើសត្វស្លាបគ្រប់ប្រភេទរួមទាំង មាន់ ទា មាន់បារាំង មាន់ទោ ក្រួច ក្ងាន និង បក្សីផ្សេងទៀត ហើយឆ្លងទៅជ្រូក និង មនុស្ស ។

## ការចំលង

- ជំងឺនេះឆ្លងពីបក្សី ទៅបក្សី តាមរយៈការប៉ះពាល់ផ្ទាល់ជាមួយនឹងលាមកសត្វ សំបោរ និង របស់ប្រើប្រាស់ដែលមានជាប់មេរោគ ដោយការដកដង្ហើមចូល ។

## រោគសញ្ញា



- ជើង ហើម របកស្រកា និង ជាំខៀវ



- ក្បាលមាន់ មានជាំពណ៌ស្វាយ

- រោគសញ្ញាផ្សេងទៀតមាន ពិបាកដកដង្ហើម ក្អក ហៀរសំបោរ រាគពីពណ៌បៃតង ទៅពណ៌ស ហើមក្បាល ។



- សត្វងាប់ច្រើន

## វិធានការ

- បើមានជួបករណីដូចរៀបរាប់ខាងលើ ត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យ ឬ ភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតអ្នកបំផុត ។

- សត្វស្លាបព្រៃ សត្វស្លាបទឹក ផ្ទុកមេរោគ និងចំលងជំងឺ ។ ក្នុងកាលៈទេសៈនេះ ហាមទិញលក់ និងប៉ះពាល់ជាបណ្ដោះអាសន្ន ។

## ការទប់ស្កាត់ការរាលដាល



- សំលាប់បក្សីឈឺ និង បក្សីដែលឆ្លងជំងឺ

- ធ្វើការរំងាប់មេរោគទ្រុង និង សំភារៈ



- ហាមឃាត់ចលនាបក្សី ចេញ-ចូល ក្នុងតំបន់ផ្ទុះជំងឺ ។
- ចាក់ថ្នាំការពារសត្វស្លាបដែលមិនទាន់ឈឺ

## វិធានការជីវសុវត្ថិភាព

- ការពារការប៉ះពាល់ជាមួយបក្សីព្រៃ
- ប្រើប្រាស់ទឹកស្អាតដែលគ្មានមេរោគ
- ជៀសវាងការដាក់បក្សីដែលចិញ្ចឹមមុន និងបក្សីដែលនាំចូលថ្មីជាមួយគ្នា ។
- អនាម័យ សំលៀកបំពាក់របស់អ្នកបំរើការនៅក្នុងកសិដ្ឋាន និង អនុញ្ញាតិតែបុគ្គលិកបំរើការឱ្យចូលក្នុងកសិដ្ឋាន។
- ជៀសវាងការធ្វើទស្សនៈកិច្ច ។
- ធ្វើការរំងាប់មេរោគ នៅក្នុងកសិដ្ឋាន និងមធ្យោបាយដឹកជញ្ជូនចេញ-ចូលកសិដ្ឋាន ។

## ការពារការចំលងមកមនុស្ស

- ជៀសវាង ការប៉ះពាល់ជាមួយបក្សីដែលសង្ស័យថាឈឺ បក្សីឈឺ និង សំលាប់បក្សីឈឺ និង បក្សីងាប់ដោយជំងឺ សំរាប់ធ្វើម្ហូប ។
- សាច់ និង ស៊ុតបក្សីគ្មានជំងឺត្រូវចំអិនឱ្យបានឆ្អិនល្អ មុននឹងបរិភោគ ។
- ជៀសវាង ចិញ្ចឹមសត្វស្លាបជាមួយនឹងជ្រូក ព្រោះមេរោគនឹងឆ្លងទៅជ្រូក រួចឆ្លងបន្តទៅមនុស្ស ។

